ការសិក្សានេះស្វែងយល់ពីរបៀបដែលស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) សម្រាប់វិស័យកសិកម្ម ស្តង់ដារគណនេយ្យអន្តរជាតិ (IAS) 41 ត្រូវបានអនុវត្តចំពោះផលិតផលកសិកម្មដ៏សំខាន់ក្នុងឧស្សាហកម្មកៅស៊ូ (ជ័រកៅស៊ូ)។ វិសាលភាពនៃការសិក្សានេះត្រូវបានកំណត់ត្រឹមក្រុម ហ៊ុនផលិតកៅស៊ូដែលមានការកែច្នៃក្រោយការប្រមូលផល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា។ កម្ពុជាជាប្រទេសមួយស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលត្រូវប្រតិបត្តិតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ឬ IFRS សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម។ សម្រាប់ការសិក្សានេះ ទិន្នន័យស្តីពីគណនេយ្យទទួលបានពីបទសម្ភាសន៍ និងការស្ទង់មតិតាមទូរស័ព្ទជាមួយគណនេយ្យករ ប្រធាន ផ្នែកហិរញ្ញវត្ថុ និងតំណាងផ្សេងទៀតរបស់ក្រុមហ៊ុនផលិតកៅស៊ូចំនួន ៩៥ នៅកម្ពុជា។ យើងរកឃើញថា ទោះបីជាមានលក្ខខណ្ឌផ្លូវច្បាប់ក្នុងការប្រតិបត្តិតាម IFRS ឬ IFRS សម្រាប់សហគ្រាសខ្នាតតូច និងមធ្យមក្តី ក៏គ្មានក្រុមហ៊ុនផលិតកៅស៊ូឧស្សាហកម្មនៅកម្ពុជាណាមួយ ដែលមានរោងចក្រកែច្នៃដែលប្រតិបត្តិតាមស្តង់ដារទាំងនេះឡើយ។ ផ្ទុយទៅវិញ ក្រុមហ៊ុនផលិតកៅស៊ូកម្ពុជានៅតែបន្តកំណត់តម្លៃជ័រកៅស៊ូរបស់ខ្លួនទៅតាមថ្លៃដើមពីមុន។

ដំបូង ឯកសារនេះនឹងបង្ហាញពីខ្លឹមសារសង្ខេបនៃឧស្សាហកម្មកៅស៊ូនៅកម្ពុជា និងក្របខ័ណ្ឌនិយ័តកម្មគណនេយ្យដែលគេប្រើប្រាស់នៅកម្ពុជា។ បន្ទាប់មក យើងនឹងពិនិត្យឡើងវិញលើលក្ខខណ្ឌតម្រូវរបស់ IAS 41 ក្នុងវិស័យកសិកម្មដែលអនុវត្តចំពោះការប្រមូលផលកៅស៊ូក្រែប បូករួមនឹងការពិភាក្សាដោយសង្ខេបពីលទ្ធផលរកឃើញ។ ផ្នែកចុងក្រោយនៃឯកសារនេះនឹងបង្ហាញពីការពិនិត្យឡើងវិញលើរបៀបដែលក្រុមហ៊ុនផលិតកៅស៊ូអាចបង្ហាញពីផលចំណេញ និងការខាតបង់ពីតម្លៃទីផ្សារពាក់ព័ន្ធនឹងផលិតផលកសិកម្ម ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដោយប្រតិបត្តិតាម IFRS។

# សេចក្តីផ្តើម

មានប្រទេសកាន់តែច្រើនកំពុងប្រើប្រាស់ IFSR នៅទូទាំងពិភពលោក។ នៅឆ្នាំ ២០១៦ មានប្រទេស ១១៩ ដែលតម្រូវឲ្យមាន IFRS សម្រាប់ក្រុមហ៊ុនភាគច្រើន ឬក្រុមហ៊ុន និងស្ថាប័នហិរញ្ញវត្ថុ ទាំងអស់ដែលបានចុះបញ្ជី (Pacter, 2016)។ ប៉ុន្តែ ការអនុវត្តស្តង់ដារអន្តរជាតិជាផ្លូវការដ៏ទូលំទូលាយនេះមិនបានធ្វើឲ្យមានការអនុវត្ត IFRS ចម្រុះឡើយ (Pacter, 2014)។ លើសពីនេះ ការសិក្សាជាច្រើនបង្ហាញថា ទោះបីប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា កម្ពុជាបានអនុវត្ត IFRS ក្តី ក៏មានករណីជាច្រើននៃការមិនប្រតិបត្តិតាម និងការលំបាកក្នុងការអនុវត្ត IFRS (Barnett, 2016: Uyar, A., M. Kilic, B. Gokcen, 2016; Albu, 2012; Trabelsi, 2016; Kihuma Ndung´u, 2012; Maina, 2010)។ ការសិក្សានេះនឹងពិនិត្យលម្អិតលើការប្រតិបត្តិតាម IFRS ក្នុងប្រទេសកម្ពុជាសម្រាប់ផលិតផលកសិកម្មដ៏សំខាន់មួយ (កៅស៊ូធម្មជាតិ) នៅពេលប្រមូលផល។

រដ្ឋាភិបាលកម្ពុជាបានចាត់ទុកឧស្សាហកម្មកៅស៊ូជាឧស្សាហកម្មដែលត្រូវលើកកម្ពស់ និងអភិវឌ្ឍ។ ផែនការអភិវឌ្ឍន៍សំខាន់ៗថ្នាក់ជាតិ (យុទ្ធសាស្ត្រចតុកោណឆ្នាំ ២០១៣ ដំណាក់កាលទី ៣ និងផែនការអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨) បានផ្តល់លក្ខខណ្ឌគាំទ្រជាច្រើនដល់ការអភិវឌ្ឍឧស្សាហកម្មកៅស៊ូ (រាជរដ្ឋាភិបាលកម្ពុជា ២០១៥, រាជរដ្ឋាភិបាលកម្ពុជា ២០១៤)។ ប៉ុន្តែយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍឧស្សាហកម្មកៅស៊ូកំពុងប្រឈមនឹងការធ្លាក់ចុះថ្លៃយ៉ាងខ្លាំង។ តម្លៃកៅស៊ូបានធ្លាក់ចុះពី ២,៥ ដុល្លា/តោន នៅខែ មករា ឆ្នាំ ២០១១ មកត្រឹម ០,៩៩ ដុល្លា/តោន នៅខែ ឧសភា ឆ្នាំ ២០១៧ (ការជួញដូរទំនិញនៅសិង្ហបុរី ២០១៧)។

ដើម្បីរក្សានិរន្តរភាពរបស់ក្រុមហ៊ុនផលិតកៅស៊ូក្នុងស្រុក និងបង្កើនប្រាក់ចំណេញ និងដើម្បីឲ្យរដ្ឋាភិបាលវាយតម្លៃឡើងវិញលើយុទ្ធសាស្ត្ររបស់ខ្លួនក្នុងការលើកកម្ពស់ឧស្សាហកម្មកៅស៊ូ គេត្រូវមានទិន្នន័យស្តីពីប្រសិទ្ធភាពការងារផ្នែកហិរញ្ញវត្ថុរបស់ឧស្សាហកម្មនេះ។ ការវាស់វែងត្រឹមត្រូវលើប្រសិទ្ធភាពការងារផ្នែកហិរញ្ញវត្ថុ ដូចជា ប្រសិទ្ធភាពការងារផ្នែកហិរញ្ញវត្ថុដែលផ្តល់ដោយ IFRS នឹងជួយឲ្យវិនិយោគិន និងអ្នកពាក់ព័ន្ធ កំណត់ថាតើផលចំណេញសមាមាត្រនឹងការវិនិយោគឬទេ។ ទិន្នន័យហិរញ្ញវត្ថុត្រឹមត្រូវនឹងជួយដល់វិនិយោគិន និងថ្នាក់គ្រប់គ្រងក្នុងការកំណត់រកមធ្យោបាយបង្កើនប្រសិទ្ធភាព និងប្រាក់ចំណេញ។ ការប្រតិបត្តិតាមស្តង់ដារគណនេយ្យអន្តរជាតិ (IAS 41) វិស័យកសិកម្ម នឹងជួយបង្កើនភាពពាក់ព័ន្ធនៃទិន្នន័យហិរញ្ញវត្ថុ (ក្រុមប្រឹក្សាភិបាលស្តង់ដារគណនេយ្យអន្តរជាតិ, 2017d; Huffman, 2014)។ គួរឲ្យសោកស្តាយដែលការស្រាវជ្រាវកន្លងមក បានបង្ហាញពីករណីជាច្រើននៃការមិនប្រតិបត្តតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ដែលជាលក្ខខណ្ឌតម្រូវនៅកម្ពុជា (Barnett, 2016)។ ការសិក្សានេះផ្តោតលើរបៀបដែលក្រុមហ៊ុនផលិតកៅស៊ូនៅកម្ពុជាប្រតិបត្តិតាមផ្នែកមួយនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ការរៀបចំគណនេយ្យសម្រាប់ផលិតផលកៅស៊ូរបស់ខ្លួន។

# វិធីសាស្ត្រ

ការសិក្សានេះផ្តោតលើចំនួនក្រុមហ៊ុនផលិតកៅស៊ូទាំងអស់នៅកម្ពុជា ដែលធ្វើការកែច្នៃក្រោយការប្រមូលផល ពោលគឺក្រុមហ៊ុនផលិតកៅស៊ូដែលប្រមូលផល និងកែច្នៃកៅស៊ូក្នុងរោងចក្រ។ យើងបានរកឃើញក្រុមហ៊ុនផលិតកៅស៊ូ ១០៥ តាមរយៈសៀវភៅបញ្ជីឈ្មោះ និងអាសយដ្ឋានទាក់ទងឆ្នាំ ២០១៧ របស់អគ្គនាយកដ្ឋានកៅស៊ូរបស់ក្រសួងកសិកម្មកម្ពុជា និងសៀវភៅបញ្ជីឈ្មោះ និងអាសយដ្ឋានទាក់ទងក្នុងអ៊ីនធឺណែតរបស់ Yellow Pages។ សៀវភៅបញ្ជីឈ្មោះ និងអាសយដ្ឋានទាក់ទងរបស់អគ្គនាយកដ្ឋានកៅស៊ូមានរោងចក្រ ១១៥ ប៉ុន្តែរោងចក្រ ១៥ គ្មានដំណើរការឡើយ។ យើងបានរកឃើញរោងចក្រ ៥ បន្ថែមទៀតក្នុងសៀវភៅបញ្ជីឈ្មោះ និងអាសយដ្ឋានទាក់ទងរបស់ Yellow Pages។ ដូច្នេះ រោងចក្រកៅស៊ូសរុបនៅកម្ពុជាមាន ១០៥។

ក្នុងចំណោមក្រុមហ៊ុនទាំង ១០៥ គណនេយ្យករ ឬតំណាងរបស់ក្រុមហ៊ុន ៤៥ បានយល់ព្រមបង្ហាញវិធីសាស្ត្រគណនេយ្យរបស់ខ្លួនសម្រាប់សារពើភណ្ឌកៅស៊ូ។ ក្នុងចំណោមក្រុមហ៊ុនទាំង ៤៥ យើងបានសម្ភាសផ្ទាល់ជាមួយក្រុមហ៊ុន ៥ ចំណែកក្រុមហ៊ុន ៤០ ទៀតត្រូវបានស្ទង់មតិតាមទូរស័ព្ទ។ យើងបានរៀបចំបទសម្ភាសន៍បន្ថែមជាមួយមន្ត្រីរដ្ឋាភិបាលម្នាក់មកពីអគ្គនាយកដ្ឋានកៅស៊ូ ប្រធានគ្រប់គ្រងរោងចក្រ ២ នាក់ ម្ចាស់រោងចក្រម្នាក់ និងគណនេយ្យកររបស់ចម្ការកៅស៊ូដែលគ្មានការកែច្នៃ។

ដោយសារការពិភាក្សាពីរបៀបដែលក្រុមហ៊ុនផលិតកៅស៊ូ អាចបង្ហាញផលចំណេញពីតម្លៃទីផ្សារក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយប្រតិបត្តិតាម IAS 41 ការសិក្សានេះយោងតាមលក្ខខណ្ឌនៃ IAS 41 និងបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនកសិកម្មដែលត្រូវបានចុះបញ្ជីនៅប្រទេសអូស្ត្រាលី អាហ្វ្រិចខាងត្បូង និងកាណាដា។

# ឧស្សាហកម្មកៅស៊ូកម្ពុជា

ផលិតកម្មកៅស៊ូនៅកម្ពុជាធ្វើឡើងភាគច្រើនបំផុតដោយក្រុមហ៊ុនឯកជន ដែលទទួលបានសម្បទានគ្រប់គ្រងលើចម្ការកៅស៊ូរបស់រដ្ឋ។ ក្រុមហ៊ុនឯកជនទាំងនេះមានសន្ទុះផលិតកម្មកើនឡើងនៅអំឡុងឆ្នាំ ២០០៩-២០១២ នៅពេលដែលតម្លៃកៅស៊ូ និងទំនិញផ្សេងទៀតបានកើនឡើងយ៉ាងគំហុក។ ក្នុងអំឡុងពេលនោះ មានការពង្រីកចម្ការកៅស៊ូយ៉ាងច្រើន (រាជរដ្ឋាភិបាលកម្ពុជា ២០១៨) ប៉ុន្តែចាប់តាំងពីឆ្នាំ ២០១២ មកតម្លៃកៅស៊ូបានធ្លាក់ចុះយ៉ាងខ្លាំង ហើយក្រុមហ៊ុនមួយចំនួនកំពុងមានបញ្ហាក្នុងការបន្តប្រតិបត្តិការរបស់ខ្លួន។ ការធ្លាក់ថ្លៃនេះបណ្ដាលមកពីកត្តាជាច្រើន ដូចជា ការធ្លាក់ចុះសេដ្ឋកិច្ចរបស់ចិន (អគ្គនាយកដ្ឋានកៅស៊ូ ២០១៦)។

ទោះបីជាមានផលចំណេញតិចក្នុងការវិនិយោគលើកៅស៊ូក្ដី ក៏ឧស្សាហកម្មនេះនៅតែជាអាទិភាពអភិវឌ្ឍន៍របស់រដ្ឋាភិបាល។ នៅឆ្នាំ ២០១៦ ផ្ទៃដីចម្ការកៅស៊ូមានប្រមាណ ៣៩៧.០០០ ហិចតា (៦៣.០០០ ហិចតា នៅឆ្នាំ ២០០៦) (អគ្គនាយកដ្ឋានកៅស៊ូ ២០១៦; Dararath, Y., N. ToP, L. Vuthy, ២០១១)។ ជាលទ្ធផល តម្លៃនៃការនាំចេញកៅស៊ូបានកើនឡើងពី ៩០,៧ លានដុល្លានៅឆ្នាំ ២០០៧ រហូតដល់ ១៥០ លានដុល្លានៅឆ្នាំ ២០១៥ (រាជរដ្ឋាភិបាលកម្ពុជា ២០១៨; Sothea, K., ២០១៦)។ យ៉ាងនេះក្ដី កៅស៊ូកម្ពុជានៅតែរួមចំណែកតិចតួចក្នុងផលិតកម្មជ័រកៅស៊ូធម្មជាតិពោលគឺប្រមាណតែ ០,៩% នៃទិន្នផលទូទាំងពិភពលោក (ក្រសួងពាណិជ្ជកម្ម ២០១២)។

ផលិតផលជ័រកៅស៊ូជិត ១០០% នៅកម្ពុជាត្រូវបាននាំចេញ ៖ ៦០% ទៅវៀតណាម, ២០% ទៅចិន, ១០% ទៅម៉ាឡេស៊ី ចំណែកភាគរយនៅសល់ត្រូវបាននាំចេញទៅប្រទេសផ្សេងទៀត (អគ្គនាយក ដ្ឋានកៅស៊ូ ២០១៦)។ ដោយសារតែការផ្គត់ផ្គង់តិច កម្ពុជាត្រូវទទួលយកតម្លៃដែលកំណត់ជាស្រេច ដោយទីផ្សារសកល ហើយកៅស៊ូកម្ពុជាត្រូវបានចាត់ទុកថាមានគុណភាពទាប។ ដូច្នេះ ទីផ្សារអន្តរជាតិបានកំណត់តម្លៃកៅស៊ូកម្ពុជាទាបជាងស្តង់ដារ ១០%-២០% (Hang 2009)។

ការផលិតកៅស៊ូនៅកម្ពុជារងគ្រោះដោយសារតម្លៃទាបក្នុងទីផ្សារអន្តរជាតិ និងថ្លៃដើមខ្ពស់ក្នុងប្រទេស។ ក្រុមហ៊ុនផលិតកៅស៊ូនៅកម្ពុជាត្រូវចំណាយថ្លៃអគ្គីសនីដល់ទៅ ២-៥ ដង ថ្លៃជាងក្រុមហ៊ុនផលិតកៅស៊ូក្នុងប្រទេសផ្សេងទៀត (Hang 2009)។ ការប្រឈមនឹងថ្លៃដើមផលិតកម្មខ្ពស់ និងតម្លៃទាប ធ្វើឲ្យឧស្សាហកម្មកៅស៊ូកម្ពុជាមានការលំបាកក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រកួតប្រជែង។ ហេតុនេះ គេត្រូវមានព័ត៌មានហិរញ្ញវត្ថុពេញលេញ និងត្រឹមត្រូវ ដើម្បីឲ្យមានការគ្រប់គ្រងដោយប្រសិទ្ធភាព ។

# ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា

នៅកម្ពុជា ច្បាប់ស្តីពីគណនេយ្យដែលបានចូលជាធរមាន និងច្បាប់ស្តីពីគណនេយ្យ សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ បានកំណត់ក្រុមប្រឹក្សាជាតិគណនេយ្យជាអ្នកកំណត់ស្តង់ដារគណនេយ្យ (ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ២០១៦)។ យោងតាមមាត្រាក្នុងច្បាប់ទាំងនេះ ស្តង់ដារគណនេយ្យត្រូវបានកំណត់ដោយក្រុមប្រឹក្សាជាតិគណនេយ្យ ប៉ុន្តែមានប្រសិទ្ធភាពនៅពេលមានប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ២០១៦)។

ចាប់តាំងពីបានធ្វើប្រតិបត្តិការនៅឆ្នាំ ២០០២ ក្រុមប្រឹក្សាជាតិគណនេយ្យកម្ពុជាបាន និងកំពុងជំរុញឲ្យមានការប្រើប្រាស់ IFRS។ ដំបូង ក្រុមប្រឹក្សាជាតិគណនេយ្យបានអនុវត្តតែស្តង់ដារមួយចំនួនរបស់ IFRS ប៉ុណ្ណោះ ប៉ុន្តែប្រកាសរបស់ក្រសួងដែលបានចេញនៅឆ្នាំ ២០០៩ បានតម្រូវឲ្យមានការអនុលោមពេញលេញតាម IFRS ហើយកាលបរិច្ឆេទអនុលោមត្រូវបានកំណត់ដោយក្រុមប្រឹក្សាជាតិគណនេយ្យ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០០៩)។ ប្រកាសរបស់ក្រសួងតម្រូវឲ្យមានការអនុវត្ត IFRS យ៉ាងពេញលេញ ប៉ុន្តែដើម្បីធានាអធិបតេយ្យភាព IFRS ត្រូវបានប្តូរឈ្មោះទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា (CIFRS)។ ជាបន្តបន្ទាប់ ក្រុមប្រឹក្សាជាតិគណនេយ្យបានចេញសេចក្តីជូនដំណឹងនៅអំឡុងខែ សីហា ឆ្នាំ ២០០៩ ដែលតម្រូវឲ្យមានការអនុលោមពេញលេញតាម CIFRS (IFRS) ឬ CIFRS សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម (IFRS សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម) ដែលបានចាប់ផ្តើមនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១២ (ក្រុមប្រឹក្សាជាតិគណនេយ្យ ២០០៩)។

យ៉ាងណាមិញ ស្តង់ដារទាំងនេះអនុវត្តតែចំពោះក្រុមហ៊ុនដែលបំពេញតាមកម្រិតជាក់លាក់ដែល បានកំណត់ក្នុងប្រកាសរបស់ក្រសួងឆ្នាំ ២០០៧ ប៉ុណ្ណោះ។ នោះគឺ*ប្រកាសរបស់ក្រសួងស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុ*។ ស្តង់ដារនេះអនុវត្តចំពោះក្រុមហ៊ុនដែលបំពេញលក្ខខណ្ឌ ២ ក្នុងចំណោមលក្ខខណ្ឌ ៣ ខាងក្រោម ៖

១. អត្រាផលចំណូលប្រចាំឆ្នាំ ៣.០០០.០០០.០០០ រៀល (ប្រហែល ៧៥០.០០០ ដុល្លា)

២. ទ្រព្យសម្បត្តិ ២.០០០.០០០.០០០ រៀល (ប្រហែល ៥០០.០០០ ដុល្លា)

៣. និយោជិតប្រចាំឆ្នាំជាមធ្យមចាប់ពី ១០០ នាក់ឡើងទៅ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មាត្រា ២ ឆ្នាំ ២០០៧)។

ក្រៅពីនេះ ក្រុមហ៊ុនទាំងអស់ដែលមានគម្រោងវិនិយោគល្អប្រសើរដែលបានចុះបញ្ជីជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវអនុវត្តតាម CIFRS ឬ CIFRS សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ដោយមិនគិតពីលក្ខខណ្ឌខាងលើឡើយ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០០៧)។

# លក្ខខណ្ឌ IFRS សម្រាប់គណនេយ្យជ័រកៅស៊ូ

ក្នុង IFRS, IAS 41 សម្រាប់វិស័យកសិកម្មជាស្តង់ដារដែលអនុវត្តចំពោះទ្រព្យសម្បត្តិជីវសាស្ត្រ និងផលិតផលកសិកម្មដែលពាក់ព័ន្ធនឹងសកម្មភាពកសិកម្ម។ IFRS បានកំណត់ទ្រព្យសម្បត្តិជីវសាស្ត្រថាជា "សត្វ ឬរុក្ខជាតិមានជីវិត" និងកំណត់ផលិតផលកសិកម្មថាជា "ផលិតផលដែលទទួលបានពីទ្រព្យសម្បត្តិជីវសាស្ត្រ" (ក្រុមប្រឹក្សាភិបាលស្តង់ដារគណនេយ្យអន្តរជាតិ កថាខណ្ឌ ៥, ២០១៧គ)។

សម្រាប់ចម្ការកៅស៊ូ ដើមឈើរស់ជាទ្រព្យសម្បត្តិជីវសាស្ត្រ ចំណែកជ័រកៅស៊ូមិនទាន់កែច្នៃជាផលិតផលកសិកម្ម។ IAS 41 បានកំណត់ដើមកៅស៊ូជាទ្រព្យសម្បត្តិជីវសាស្ត្រ ចំណែកផលិតផលកៅស៊ូជាផលិតផលកសិកម្ម (ក្រុមប្រឹក្សាភិបាលស្តង់ដារគណនេយ្យអន្តរជាតិ កថាខណ្ឌ ៤, ២០១៧គ)។ ប៉ុន្តែ IAS 41 បានផាត់ដើមកៅស៊ូចេញពីគណនេយ្យតម្លៃទីផ្សារក្នុងនាមជារុក្ខជាតិដែលប្រមូលផលបានលើសពី ២ ដងក្នុងមួយឆ្នាំ។ កថាខណ្ឌទី ២ របស់ IAS 41 ចែងថា IAS 41 មិនអនុវត្តចំពោះរុក្ខជាតិដែលប្រមូលផលបានលើសពី ២ ដងក្នុងមួយឆ្នាំ ហើយដើមកៅស៊ូផ្តល់ផលលើសពីម្តង។ ប៉ុន្តែដើមកៅស៊ូត្រូវបានកំណត់ក្នុង IAS 16 ៖ ទ្រព្យសម្បត្តិ រុក្ខជាតិ និងសម្ភារ (ក្រុមប្រឹក្សាភិបាលស្តង់ដារគណនេយ្យអន្តរជាតិ កថាខណ្ឌ ២, ២០១៧គ)។

ក្នុង IFRS ផលិតផលកសិកម្ម ដូចជា ជ័រកៅស៊ូត្រូវបានវាស់វែងទៅតាមតម្លៃទីផ្សារនៅពេលប្រមូលផល "ផលិតផលកសិកម្មដែលប្រមូលផលបានពីទ្រព្យសម្បត្តិជីវសាស្ត្ររបស់ក្រុមហ៊ុន ត្រូវបានវាស់វែងទៅតាមថ្លៃដើមទាបធៀបនឹងតម្លៃទីផ្សារក្នុងការលក់នៅពេលប្រមូលផល" (ក្រុមប្រឹក្សាភិបាលស្តង់ដារគណនេយ្យអន្តរជាតិ កថាខណ្ឌ ១៣, ២០១៧គ)។ តម្លៃទីផ្សារក្នុង IFRS គឺជា "តម្លៃដែលទទួលបានដើម្បីលក់ទ្រព្យសម្បត្តិមួយ ............ ក្នុងប្រតិបត្តិការដែលមានការរៀបចំរវាងអ្នកចូលរួមក្នុងទីផ្សារ" (ក្រុមប្រឹក្សាភិបាលស្តង់ដារគណនេយ្យអន្តរជាតិ កថាខណ្ឌ ៩, ២០១៧ខ)។

នៅពេលវាស់វែងផលិតផលកសិកម្មធៀបនឹងតម្លៃទីផ្សារនៅពេលប្រមូលផល គេនឹងវាស់វែងពីផលចំណេញ ឬការខាតបង់ ប៉ុន្តែជ័រកៅស៊ូដែលមិនបានប្រមូលផល នឹងមិនត្រូវបានទទួលស្គាល់ជាមុនឡើយ ដោយសារតែគេមិនអាចវាស់វែងជ័រកៅស៊ូដែលស្ថិតក្នុងសំបកដើម កៅស៊ូបាន (Fletcher, P., 2015; ក្រុមប្រឹក្សាភិបាលស្តង់ដារគណនេយ្យម៉ាឡេស៊ី ២០១៣)។ មានន័យថា មានផលចំណេញពីការទទួលស្គាល់ពីដំបូងចំពោះជ័រកៅស៊ូនៅពេលប្រមូលផល។ ក្នុង IFRS ផលចំណេញពីការទទួលស្គាល់ជ័រកៅស៊ូដែលបានប្រមូលផល ត្រូវបានកត់ត្រាជាប្រាក់ចំណូល។ ក្នុងលក្ខខណ្ឌតម្រូវរបស់ IAS 41 "ផលចំណេញ ឬការខាតបង់ពីការទទួលស្គាល់ពីដំបូងចំពោះផលិតផលកសិកម្មដែលមានថ្លៃដើមទាបធៀបនឹងតម្លៃទីផ្សារក្នុងការលក់ ត្រូវរួមបញ្ចូលក្នុង

ប្រាក់ចំណេញ ឬការខាតបង់សម្រាប់អំឡុងពេលពាក់ព័ន្ធ" (ក្រុមប្រឹក្សាភិបាលស្តង់ដារគណនេយ្យអន្តរជាតិ កថាខណ្ឌ ២៨, ២០១៧គ)។

ក្រោយការប្រមូលផល និងការវាស់វែងថ្លៃដើមទាបធៀបនឹងតម្លៃទីផ្សារក្នុងការលក់ គណនី IFRS សម្រាប់ជ័រកៅស៊ូគឺជាសារពើភណ្ឌក្នុងសារពើភណ្ឌ IAS 2 (ក្រុមប្រឹក្សាភិបាលស្តង់ដារគណនេយ្យអន្តរជាតិ កថាខណ្ឌ ៣, ២០១៧គ)។ ថ្លៃដើមទាបធៀបនឹងតម្លៃទីផ្សារក្នុងការលក់ បានក្លាយជាថ្លៃដើមដំបូងរបស់សារពើភណ្ឌនេះ។ ថ្លៃដើមនេះនឹងកើនឡើងនៅពេលគេបន្ថែមថ្លៃដើមនៃការកែច្នៃទៅក្នុងថ្លៃដើមសារពើភណ្ឌ។ IAS 2 តម្រូវឲ្យមានការកត់ត្រាសារពើភណ្ឌទៅតាមថ្លៃដើម ដែលរួមបញ្ចូលថ្លៃដើមទាំងអស់ក្នុងការរៀបចំសារពើភណ្ឌរបស់ទីតាំង និងលក្ខខណ្ឌបច្ចុប្បន្ន (ក្រុមប្រឹក្សាភិបាលស្តង់ដារគណនេយ្យអន្តរជាតិ កថាខណ្ឌ ១០, ២០១៧ក)។ សម្រាប់ចម្ការកៅស៊ូ វាមានន័យថា រាល់ថ្លៃដើមនៃការកែច្នៃធម្មតាទាំងអស់ ដូចជា កម្លាំងពលកម្ម សារធាតុគីមី ឥន្ធនៈ និងអប្បហារ នឹងត្រូវបានបន្ថែមក្នុងថ្លៃដើម។ ប៉ុន្តែក្នុង IFRS ថ្លៃដើមរបស់សារពើភណ្ឌ មិនអាចធំជាងតម្លៃទ្រព្យពិតរបស់សារពើភណ្ឌបានឡើយ (ក្រុមប្រឹក្សាភិបាលស្តង់ដារគណនេយ្យអន្តរជាតិ កថាខណ្ឌ ៩, ២០១៧ក)។

# លទ្ធផលរកឃើញ ៖ គណនេយ្យក្រុមហ៊ុនផលិតកៅស៊ូកម្ពុជា (ជ័រកៅស៊ូ)

តាមរយៈបទសម្ភាសន៍ផ្ទាល់ និងការស្ទង់មតិតាមទូរស័ព្ទ យើងរកឃើញថា ក្រុមហ៊ុនផលិតកៅស៊ូទាំង ៩៥ ដែលបានចូលរួមក្នុងការសិក្សា សុទ្ធតែបានអនុវត្ត IAS 41 សម្រាប់វិស័យកសិកម្ម។ គួរកត់សម្គាល់ថា ដោយសារតែយើងរកឃើញក្រុមហ៊ុនផលិតកៅស៊ូតែ ១០៥ ដែលមានការកែច្នៃផលិតផលក្នុងប្រទេសកម្ពុជា ចំនួនក្រុមហ៊ុនផលិតកៅស៊ូទាំង ៩៥ គឺជាអត្រាដ៏ខ្ពស់។

ក្រុមហ៊ុនភាគច្រើនបានប្រើប្រាស់គោលនយោបាយ និងវិធីសាស្ត្រគណនេយ្យពីមុនរបស់ខ្លួន ពោលគឺការរៀបចំគណនេយ្យដំណាំកៅស៊ូទៅតាមថ្លៃដើម។ ក្រុមហ៊ុន ៣៧ ប្រើប្រាស់ការវាស់វែងថ្លៃដើមពីមុន ប៉ុន្តែក្រុមហ៊ុន ៨ ពោលគឺក្រុមហ៊ុនខ្នាតតូចលក្ខណៈគ្រួសារ រាយការណ៍ថា មិនបានប៉ុនប៉ងគណនាថ្លៃដើមពីមុនឡើយ។

សម្រាប់ក្រុមហ៊ុនផលិតកៅស៊ូដែលកត់ត្រាថ្លៃដើមសារពើភណ្ឌ ឯកតាគណនេយ្យសារពើភណ្ឌគឺជាទិន្នផលរបស់រោងចក្រ ដែលជាផលិតផលកៅស៊ូកែច្នៃចម្រុះ ដូចជា កៅស៊ូក្រែប បន្ទះកៅស៊ូស្ងួត ឬផលិតផលកៅស៊ូដែលកំណត់តាមលក្ខណៈបច្ចេកទេស។ គ្មានកំណត់ត្រាគណនេយ្យសម្រាប់ជ័រកៅស៊ូឆៅដែលបានប្រមូលផល ឬវឌ្ឍនភាពប្រតិបត្តិការឡើយ ប៉ុន្តែមានកំណត់ត្រានៃការបញ្ជាទិញសម្រាប់កៅស៊ូក្រែបដែលបានទិញពីអ្នកដាំកៅស៊ូផ្សេងទៀត។ សម្រាប់សារពើភណ្ឌ ក្រុមហ៊ុនទាំងនេះមានតែកំណត់ត្រាតម្លៃសម្រាប់ផលិតផលសម្រេច ដែលអាចលក់បានប៉ុណ្ណោះ។

ក្រុមហ៊ុនផលិតកៅស៊ូទាំងនេះគណនាថ្លៃដើមសារពើភណ្ឌរបស់ផលិតផលសម្រេច ១ តោន ដោយប្រើប្រាស់រូបមន្តខាងក្រោម ៖

| |
|---|
| ថ្លៃដើមរបស់កៅស៊ូកែច្នៃ ១ តោន = ថ្លៃដើមទាំងអស់/ខែ (ផាត់ចេញថ្លៃដើមធ្វើមូលធនកម្មពាក់ព័ន្ធនឹងដើមកៅស៊ូថ្មី) ÷ ទិន្នផល/ខែ (តោន) |

ក្នុងការប្រើប្រាស់រូបមន្តខាងលើ ក្រុមហ៊ុនទាំងនេះមិនបានរាយការណ៍ពីភាពខុសគ្នារវាងថ្លៃដើមធម្មតា និងថ្លៃដើមខុសធម្មតាឡើយ។ ថ្លៃដើមទាំងអស់ លើកលែងតែថ្លៃដើមធ្វើមូលធនកម្ម ត្រូវបានរួមបញ្ចូលក្នុងសារពើភណ្ឌ។ មានន័យថា ក្នុងរយៈពេលប៉ុន្មានខែដែលមានទិន្នផលខ្ពស់ និងប្រសិទ្ធភាពខ្ពស់ ថ្លៃដើម/តោនគឺទាប ខណៈដែលនៅរយៈពេលប៉ុន្មានខែដែលមានទិន្នផលទាប ថ្លៃដើម/តោន គឺខ្ពស់ (ខ្ពស់ជាង ១.០០០.០០០ ដុល្លាសម្រាប់ក្រុមហ៊ុនមួយ)។

ថ្លៃដើមសារពើភណ្ឌដែលកំណត់ដោយរូបមន្តខាងលើ ត្រូវបានកត់ត្រាក្នុងសារពើភណ្ឌដែលធ្វើឡើងពីមួយខែទៅមួយខែ រហូតដល់ការលក់ចេញ។ នៅពេលគេបានលក់សារពើភណ្ឌ វានឹងត្រូវ

បានកត់ត្រាជាចំណាយ។ ការលក់មានលក្ខណៈជាដំណាក់កាល និងតាមឱកាស (ក្រុមហ៊ុននានារាយការណ៍ថា មានការលក់ ២-៥ ដង/ឆ្នាំ នៅពេលមានការចុះកិច្ចព្រមព្រៀងជាមួយអ្នកលក់)។ ខណៈដែលសារពើភណ្ឌស្ថិតនៅក្នុងស្តុករង់ចាំការលក់ ក្រុមហ៊ុននានាមិនបានកត់ត្រាតម្លៃសារពើភណ្ឌឡើយ ទោះបីជាតម្លៃក្នុងទីផ្សារអាចនឹងធ្លាក់ចុះក៏ដោយ។ ដូច្នេះ ថ្លៃដើមសារពើភណ្ឌស្ថិតនៅដដែលរហូតដល់ពេលលក់។ ទោះបីជាមានការផ្តោតសំខាន់លើថ្លៃដើមសម្រាប់ការរៀបចំគណនេយ្យក្តី ក៏ប្រធានគ្រប់គ្រង និងម្ចាស់អាជីវកម្មរាយការណ៍យ៉ាងសកម្មពីការពិនិត្យតាមដាន និងការសម្រេចចិត្តដោយផ្អែកលើតម្លៃទីផ្សារនៃសារពើភណ្ឌរបស់ខ្លួន។

# គុណសម្បត្តិនៃការប្រើប្រាស់ IFRS

តម្លៃសារពើភណ្ឌ និងការវាស់វែងប្រាក់ចំណេញ ឬការខាតបង់ នឹងជួយឲ្យថ្នាក់គ្រប់គ្រង និងវិនិយោគិនសម្រេចចិត្តពីការប្រើប្រាស់ធនធាន ការរៀបចំថវិកា និងការកំណត់ថ្លៃ។ ជាសំណាងមិនល្អ វិធីសាស្ត្រថ្លៃដើមពីមុន មានចំណុចខ្សោយជាច្រើនដែលអាចដោះស្រាយបានដោយប្រើប្រាស់រង្វាស់តម្លៃទីផ្សារក្នុង IAS 41។ ចំណុចខ្សោយទាំងនេះ រួមមាន ៖

១. **សារពើភណ្ឌថ្លៃដើមពីមុន មិនឆ្លុះបញ្ចាំងពីតម្លៃពិតប្រាកដ ៖** ការអនុវត្តបច្ចុប្បន្នរបស់ក្រុមហ៊ុនផលិតកៅស៊ូកម្ពុជា កត់ត្រាសារពើភណ្ឌដែលលើស ឬទាបខ្លាំងជាងតម្លៃទីផ្សារ។ សារពើភណ្ឌអាចមានតម្លៃខ្ពស់ជ្រុលពេកក្នុងអំឡុងពេលដែលផលិតកម្មធ្លាក់ចុះ។ ហេតុនេះហើយទើបតម្លៃគណនេយ្យរបស់សារពើភណ្ឌ មិនត្រូវបានប្រើប្រាស់ក្នុងការព្យាករណ៍លំហូរសាច់ប្រាក់ ឬការសម្រេចចិត្តឡើយ។ ផ្ទុយទៅវិញ ថ្នាក់គ្រប់គ្រង និងវិនិយោគិន ធ្វើការព្យាករណ៍ពីលំហូរសាច់ប្រាក់ និងសម្រេចចិត្តដោយប្រើប្រាស់តម្លៃទីផ្សារ និងមិនខ្វល់ពីព័ត៌មានគណនេយ្យនោះទេ។

២. **ថ្លៃដើមពីមុនមិនញែកដាច់ពីគ្នារវាងផលចំណេញដោយសារការប្រែប្រួលតម្លៃទីផ្សារ និងផលចំណេញពីផលិតកម្មតម្លៃបន្ថែមឡើយ ៖** នៅពេលក្រុមហ៊ុនផលិតកៅស៊ូនៅកម្ពុជាប្រើប្រាស់វិធីសាស្ត្រថ្លៃដើមពីមុន ប្រាក់ចំណេញត្រូវបានកំណត់ជាភាពខុសគ្នារវាងតម្លៃលក់ និងថ្លៃដើមសរុប ដោយផាត់ចេញថ្លៃដើមលើការដាំដុះ។ ប្រាក់ចំណេញនេះរួមបញ្ចូលផលចំណេញនៃផលិតកម្មកៅស៊ូក្រែប និងផលចំណេញតម្លៃបន្ថែមពីការកែច្នៃកៅស៊ូក្រែប។ ដូច្នេះ វិនិយោគិន ឬប្រធានគ្រប់គ្រងមិនច្បាស់ពីតម្លៃដែលត្រូវបានបូកបន្ថែមដោយដំណើរការផលិតកម្មឡើយ។
ចំណុចនេះអាចជះឥទ្ធិពលអវិជ្ជមានលើភាពទាន់ពេលវេលា និងប្រសិទ្ធភាពនៃការសម្រេចចិត្តលើការកែច្នៃ ឬការវិនិយោគលើការកែច្នៃ។

៣. **គណនេយ្យថ្លៃដើមពីមុនមិនប្រតិបត្តិតាមច្បាប់ ៖** ច្បាប់កម្ពុជាតម្រូវឲ្យក្រុមហ៊ុននានាអនុវត្តតាម CIFRS ឬ CIFRS សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ប៉ុន្តែការរៀបចំគណនេយ្យបច្ចុប្បន្នមិនអនុវត្តតាមស្តង់ដារទាំងនេះឡើយ។

# គុណវិបត្តិរបស់ IFRS

ការប្រើប្រាស់ IFRS ក៏មានគុណវិបត្តិមួយចំនួនផងដែរ។ ទីមួយ មានហានិភ័យដែលអត្ថប្រយោជន៍នៃប្រសិទ្ធភាពក្នុងការគ្រប់គ្រងពីព័ត៌មានបន្ថែម មិនសំខាន់ជាងពេលវេលា និងថ្លៃចំណាយនៃការផ្លាស់ប្តូរវិធីសាស្ត្រគណនេយ្យដែលមានជាធរមាន។ ដោយសារវិធីសាស្ត្រថ្លៃដើមដែលប្រើប្រាស់ដោយក្រុមហ៊ុនផលិតកៅស៊ូផ្តល់ស្តង់ដារ ដែលអាចផ្ទៀងផ្ទាត់បានសម្រាប់ ការកត់ត្រាប្រតិបត្តិការ និងបង្ហាញពីរង្វាស់ប្រាក់ចំណេញ វិនិយោគិនអាចយល់ថា ចំណុចនេះអាចគ្រប់គ្រាន់ ក្នុងការបំពេញគោលបំណងរបស់ខ្លួនបាន។ ទីពីរ អាចមានការបាត់បង់នូវភាពអាចប្រៀបធៀបបានជាមួយព័ត៌មានហិរញ្ញវត្ថុរបស់ឆ្នាំមុនៗ។ ទីបី ប្រសិនបើគណនេយ្យករហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមិនយល់ដឹងពី IFRS ពួកគេប្រហែលជាត្រូវចំណាយប្រាក់ជួលទីប្រឹក្សា និងអ្នកផ្តល់យោបល់បច្ចេកទេស ឲ្យជួយបង្កើតនីតិវិធីសម្រាប់ការកត់ត្រា និងបង្ហាញព័ត៌មានដែលប្រតិបត្តិតាម IFRS។

# ការប្រើប្រាស់ IAS 41 ក្នុងការប្រមូលផលជ័រកៅស៊ូ តម្លៃទីផ្សាររបស់ជ័រកៅស៊ូដែលបានប្រមូលផល

យោងតាម IAS 41 ផលិតផលកសិកម្ម ដូចជា ជ័រកៅស៊ូ ត្រូវបានកត់ត្រាទៅតាមថ្លៃដើមប៉ាន់ស្មានទាបធៀបនឹងតម្លៃទីផ្សារក្នុងការលក់ នៅពេលប្រមូលផល។ តម្លៃទីផ្សារត្រូវបានកត់ត្រាជាប្រាក់ចំណូលក្នុងរបាយការណ៍ប្រាក់ចំណេញ ឬការខាតបង់។ ថ្លៃដើមប៉ាន់ស្មានទាបធៀបនឹងតម្លៃទីផ្សារក្នុងការលក់ ត្រូវបានវាស់វែងភ្លាមៗក្រោយពេលប្រមូលផល។ IAS 41 លើកឡើងថា ការកើនឡើងតម្លៃទីផ្សារដោយសារការប្រមូលផល ត្រូវបានកំណត់ដោយតម្លៃទីផ្សារនៅពេលប្រមូលផល។ កថាខណ្ឌ ២៩ របស់ IAS 41 គូសបញ្ជាក់ថា "អាចមានផលចំណេញ ឬការខាតបង់ដោយសារការទទួលស្គាល់ពីដំបូងលើផលិតផលកសិកម្មដោយសារការប្រមូលផល" (ក្រុមប្រឹក្សាភិបាលស្តង់ដារគណនេយ្យអន្តរជាតិ កថាខណ្ឌ ២៩, ២០១៧គ)។ ដូច្នេះ ថ្លៃដើមក្នុង ពេលប្រមូលផលអាចកំណត់ជាការចំណាយ។

IFRS អាចឲ្យគេវាស់វែងផលចំណេញពីតម្លៃទីផ្សាររបស់ផលិតផលកសិកម្ម ទៅតាមថ្លៃដើមសរុប ឬដុលក្នុងការដាំដុះ។ ប្រសិនបើក្រុមហ៊ុនផលិតកៅស៊ូសម្រេចបង្ហាញផលចំណេញពីថ្លៃដើមដុលក្នុងការដាំដុះ ការកត់ត្រាចំណាយដែលពាក់ព័ន្ធនឹងការអប្បហារថ្លៃដើមធ្វើមូលធនកម្មរបស់រុក្ខជាតិដែលប្រមូលផលបានលើសពី ២ ដងក្នុងមួយឆ្នាំ ការបណ្តុះកូនឈើ និងការប្រមូលផលនឹងត្រូវបានកត់ត្រាដូចខាងក្រោម ៖

| | ពាន់ដុល្លា | ពាន់ដុល្លា |
|---|---|---|
| **ចំណាយ (Dr)** | ៥០០ | |
| **អប្បហារបង្គរ/សាច់ប្រាក់/គណនីដែលត្រូវសង (Cr)** | | ៥០០ |

ការបញ្ចូលក្នុងទិន្នានុប្បវត្តន៍សម្រាប់ការទទួលស្គាល់ជ័រកៅស៊ូដែលបានប្រមូលផល នឹងត្រូវបានកត់ត្រាដូចខាងក្រោម ៖

| | ពាន់ដុល្លា | ពាន់ដុល្លា |
|---|---|---|
| **សារពើភណ្ឌ (Dr)** | ៥០០ | |
| **ផលចំណេញពីតម្លៃទីផ្សារ (Cr) លើការទទួលស្គាល់ផលិតផលកសិកម្ម** | | ៥០០ |

ដើម្បីជួយដល់ការកំណត់ថ្លៃដើមទាបធៀបនឹងតម្លៃទីផ្សារក្នុងការលក់របស់ជ័រកៅស៊ូ ដែលប្រមូលផលបាន ក្រុមហ៊ុនផលិតកៅស៊ូកម្ពុជាអាចពិចារណាពីតម្លៃទីផ្សារដែលត្រូវបានរាយការណ៍ក្នុងព្រឹត្តិប័ត្រតម្លៃទីផ្សារប្រចាំខែ ដែលបង្ហោះក្នុងអ៊ីនធើរណែតរបស់អគ្គនាយកដ្ឋានកៅស៊ូ។ ព្រឹត្តិប័ត្រប្រចាំខែបង្ហាញពីតម្លៃប្រចាំខែ និងប្រចាំសប្តាហ៍នៅកម្ពុជា សម្រាប់ជ័រកៅស៊ូស្ងួត និងរាវតាមខេត្ត។

## សារពើភណ្ឌតម្លៃក្រោយពេលប្រមូលផល

ក្រោយពេលប្រមូលផល គណនេយ្យកៅស៊ូស្ថិតក្នុងសារពើភណ្ឌ IAS 2។ ដូច្នេះ រាល់ថ្លៃដើមពាក់ព័ន្ធនឹងការកែច្នៃ ដូចជា សារធាតុគីមី ប្រាក់ឈ្នួលកម្មករ ឥន្ធនៈ និងអប្បហារ នឹងត្រូវបានបន្ថែមលើថ្លៃដើមសារពើភណ្ឌ។ ប៉ុន្តែក្រុមហ៊ុនផលិតកៅស៊ូកម្ពុជាត្រូវកត់សម្គាល់ថា ថ្លៃដើមខុសធម្មតា និងថ្លៃដើមដែលមិនពាក់ព័ន្ធនឹងផលិតកម្មនឹងក្លាយជាចំណាយ និងមិនត្រូវបានបូកបន្ថែមលើថ្លៃដើមសារពើភណ្ឌឡើយ។ ឧ. ប្រសិនបើក្នុងអំឡុងខែណាមួយ រោងចក្រធ្វើប្រតិបត្តិការ ២០% លើសពីសមត្ថភាពពេញលេញធម្មតារបស់ខ្លួន រោងចក្រនោះអាចបញ្ចូលថ្លៃដើមរោងចក្រតែ ២០% ប៉ុណ្ណោះក្នុងតម្លៃសារពើភណ្ឌ ចំណែកថ្លៃដើម ៨០% ទៀតគឺជាចំណាយ។

# ការបង្ហាញក្នុងរបាយការណ៍ប្រាក់ចំណេញ ឬការខាតបង់

ផលចំណេញពីតម្លៃទីផ្សារលើការទទួលស្គាល់ពីដំបូងចំពោះផលិតផលកសិកម្ម ត្រូវបានកំណត់ជាប្រាក់ចំណូល ប៉ុន្តែមិនមែនផលចំណូលឡើយ។ ផលចំណូលត្រូវបានបង្ហាញដាច់ដោយឡែក។ យោងតាម IAS 1 របាយការណ៍ប្រាក់ចំណេញ ឬការខាតបង់ អាចបង្ហាញដោយចំណាយដែលកំណត់តាមមុខងារ ឬលក្ខណៈ។ ខាងក្រោមនេះជាការបង្ហាញយ៉ាងល្អនូវផលចំណេញដុលពីតម្លៃទីផ្សារ ៖

| | ពាន់ដុល្លា |
|---|---|
| ផលចំណូល | X |
| ថ្លៃដើមនៃការលក់ | (X) |
| ផលចំណេញពីតម្លៃទីផ្សារលើការប្រមូលផលកៅស៊ូក្រែប | X |
| ថ្លៃដើមលើការដាំដុះ និងការប្រមូលផល | (X) |
| ប្រាក់ចំណេញដុល | X |
| ចំណាយរដ្ឋបាល | (X) |
| ថ្លៃដើមហិរញ្ញវត្ថុ | (X) |
| ប្រាក់ចំណេញមុនគិតពន្ធ | X |
| ពន្ធលើប្រាក់ចំណូល | (X) |
| ប្រាក់ចំណេញ/ឆ្នាំ | X |

តាមវិធីនេះ តម្លៃបន្ថែមពីការកែច្នៃត្រូវបានបង្ហាញជាប្រាក់ចំណេញដុល ចំណែកផលចំណេញពីការប្រមូលផលជ័រកៅស៊ូត្រូវបានបង្ហាញជាផលចំណេញពីតម្លៃទីផ្សារ។ ការបង្ហាញនេះរួមបញ្ចូលវិធីសាស្ត្រចំណាយតាមមុខងារ។ ការលើកឡើងនេះត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនកសិកម្មដែលបានចុះបញ្ជីជាសាធារណៈជាច្រើន ដូចជា ក្រុមហ៊ុន Australia Agricultural Company ក្រុមហ៊ុន New Zealand King Salmon និងក្រុមហ៊ុន Canopy Growth Corporation របស់កាណាដា។ ក្នុងការលើកឡើងនេះ ក្រុមហ៊ុនផលិតកៅស៊ូអាចបង្ហាញនូវបន្ទាត់ចំណាយបន្ថែម ឬប្រាក់ចំណូលដែលពាក់ព័ន្ធ និងជួយដល់ការសម្រេចចិត្ត។ ក្រៅពីនេះ ក្រុមហ៊ុនអាចលុបចោលប្រាក់ចំណូលដុល រួចចែកដាច់ពីគ្នារវាងប្រាក់ចំណូល និងចំណាយ។

ក្រៅពីវិធីសាស្ត្រចំណាយតាមមុខងារ គេក៏អាចប្រើប្រាស់វិធីសាស្ត្រចំណាយតាមលក្ខណៈបានផងដែរ។ នៅពេលប្រើប្រាស់វិធីសាស្ត្រនេះ របាយការណ៍ប្រាក់ចំណេញ ឬការខាតបង់អាចបង្ហាញដូចខាងក្រោម ៖

| | ពាន់ដុល្លា |
|---|---|
| ផលចំណូល | X |
| ផលចំណេញពីតម្លៃទីផ្សារលើការប្រមូលផលជ័រកៅស៊ូ | X |
| ការផ្លាស់ប្តូរសារពើភណ្ឌ | X |
| ការអនុវត្តការងាររបស់ក្រុមហ៊ុន និងការធ្វើមូលធនកម្ម | X |
| ការប្រើប្រាស់វត្ថុធាតុដើម និងវត្ថុធាតុដែលអាចប្រើប្រាស់បាន | (X) |
| អត្ថប្រយោជន៍និយោជិត | (X) |
| អប្បហារ | (X) |
| ចំណាយផ្សេងទៀត | (X) |
| ថ្លៃដើមហិរញ្ញវត្ថុ | (X) |
| ប្រាក់ចំណេញមុនគិតពន្ធ | X |
| ពន្ធលើប្រាក់ចំណូល | (X) |
| ប្រាក់ចំណេញ/ឆ្នាំ | X |

ការលើកឡើងនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដោយក្រុមហ៊ុនកសិកម្មអូស្ត្រាលីដែល បានចុះបញ្ជីជាសាធារណៈ ដូចជា Sterling Plantation Limited, Costa Group Holdings, Huon Aquaculture Group Limited និង Tasfoods Limited។

## សេចក្តីសន្និដ្ឋាន

ខណៈដែលគណនេយ្យបច្ចុប្បន្នដែលប្រើប្រាស់ដោយក្រុមហ៊ុនផលិតកៅស៊ូផ្សេងទៀត ផ្តល់ការវាស់វែងពីប្រាក់ចំណេញរួម ការអនុលោមតាម IFRS ដោយរៀបចំគណនេយ្យជ័រកៅស៊ូទៅតាមតម្លៃទីផ្សារនៅពេលប្រមូលផល អាចបង្ហាញបានល្អប្រសើរដល់ប្រធានគ្រប់គ្រង និងវិនិយោគិនពីតម្លៃបន្ថែម និងកង្វះប្រសិទ្ធភាពដែលត្រូវដោះស្រាយក្នុងផ្នែកកែច្នៃក្នុងអាជីវកម្មរបស់ខ្លួន ធៀបនឹងសកម្មភាពកសិកម្ម និងការប្រមូលផល។ ទន្ទឹមនឹងនេះ ការប្រតិបត្តិតាម IFRS នឹងបង្កើនភាពត្រឹមត្រូវនៃប្រាក់ចំណេញ និងកាត់បន្ថយហានិភ័យនៃការកំណត់តម្លៃសារពើភណ្ឌខ្ពស់ហួសហេតុ។ ចុងបញ្ចប់ ការអនុលោមតាម IFRS នឹងធ្វើឲ្យការរៀបចំគណនេយ្យអនុលោតាមច្បាប់ជាតិ និងស៊ីសង្វាក់គ្នានឹងគណនេយ្យរបស់ក្រុមហ៊ុនជាតិ និងអន្តរជាតិផ្សេងទៀត។

# ឯកសារយោង


Albu, N.; Albu, C. (2012). International Financial Reporting Standards in an Emerging Economy: Lessons from Romania. *Australian Accounting Review*, No. 63 Vol. 22, Issue 4, 2012, pp 341 - 352. Retrieved from: https://www.researchgate.net/publication/256044793_International_Financial_Reporting_Standards_in_an_Emerging_Economy_Lessons_from_Romania

Barnett, C. (2016). Report on Implementation of Accounting Standards and Statutory Audits in the Kingdom of Cambodia. National Accounting Council. Retrieved from http://www.cam-ed.com/docs/IFRS_Research_Report_July_2016.pdf

Dararath, Y.; Top, N.; Lic, V. (2011). Rubber Plantation Development in Cambodia: At What Cost? Retrieved from: https://surumer.uni-hohenheim.de/fileadmin/einrichtungen/surumer/Rubber_Plantation_Development_in_Cambodia.pdf

Fletcher, P. (2015). International Accounting Standards 41 [opinion letter]. 2 February 2015, London: The Tropical Growers' Association. Retrieved from: http://www.mpevans.co.uk/mpevans/uploads/finreports/tga-opinion-2.pdf

General Directorate for Rubber. (2016). Report on Results of 2015 and Direction for 2016 of the General Directorate for Rubber.

Hang, S.C. (2009). Export competitiveness of the Cambodian rubber sector relative to other Greater Mekong Subregion suppliers: A simple descriptive analysis. ARTNeT Greater Mekong Subregion (GMS) Initiative Discussion Paper Series, No. 1.

Huffman, A. (2014). Matching Measurement to Asset Use: Evidence from IAS 41. https://business.lsu.edu/Accounting/Documents/Seminar%20Series/Huffman,%20Adrienna%20-%20LSU%20November.pdf

International Accounting Standards Board. (2009). Module 34 - Specialised Activities. IFRS Foundation Training Material for the IFRS for SMEs, IASB: London, UK. Retrieved from: http://www.ifrs.org/IFRS-for-SMEs/Documents/IFRS%20for%20SMEs%20Modules/Module_34_Specialised_Activities__version%202013.pdf

International Accounting Standards Board. (2017a). IAS 2 Inventory. In *IFRS Standards* (Vol. A). London, UK: IASB.

International Accounting Standards Board. (2017b). IFRS 13 Fair Value. In *IFRS Standards* (Vol. A). London, UK: IASB.

International Accounting Standards Board. (2017c). IAS 41 Agriculture. In *IFRS Standards* (Vol. A). London, UK: IASB.

International Accounting Standards Board. (2017d). IAS 41 Agriculture. In *IFRS Standards* (Vol. B). London, UK: IASB.

Kihumba N'Dungu, J. (2012). The Extent of Compliance with IAS 41 by Limited Agricultural Companies Listed on the Nairobi Securities Exchange. Retrieved from http://erepository.uonbi.ac.ke/bitstream/handle/11295/13730/JACKSON_KIHUMBA_NDUNGU_MBA_2012.pdf?sequence=2

Law on Accounting and Auditing. (2016). Royal Government of Cambodia, April 11, 2016, Phnom Penh.

Maina, P. (2010). Fair Value Reporting Challenges Facing Small and Medium-Sized Entities in the Agricultural Sector in Kenya [dissertation]. Retrieved from: http://uir.unisa.ac.za/bitstream/handle/10500/4093/dissertation_maina_p.pdf?sequence=1

Malaysian Accounting Standards Board. (2013). Exposure Draft ED/2013/8 - Agriculture: Bearer Plants [comment letter]. 28 October 2013, Malaysia. Retrieved from: http://www.masb.org.my/pdf.php?pdf=CL_IASB_ED2013_8_Bearer-Plants.pdf&file_path=pdf

Ministry of Commerce of Cambodia. (2012). Rubber Sector Profile - Draft. Retrieved from: http://www.moc.gov.kh/TradeSwap/userfiles/Media/file/Projects/TDSP/Top%20Ten%20Products/2012-07-26%20Rubber%20Sector%20profile.pdf

Ministry of Economy and Finance (2007). Ministerial Decree on Obligation of Submission of Financial Statements for Audit. 26 July 2007, Phnom Penh.

Ministry of Economy and Finance (2009). Ministerial Decree on Promulgation of Cambodian Financial Reporting Standards. 8 January 2009, Phnom Penh.

National Accounting Council. (2009). Notification on Setting for Use Cambodian Financial Reporting Standards and Cambodian International Financial Standards for Small and Medium Sized Entities. August 28, 2009, Phnom Penh.

Pactor, P. (2014). Global Accounting Standards - From Vision to Reality. *The CPA Journal*, January 2014, pp 6 - 10. Retrieved from: http://www.ifrs.org/Alerts/Publication/Documents/2014/CPA-Journal-Global-Accounting-Standards-January-2014.pdf

Pactor, P. (2016). Pocket Guide to IFRS Standards: the global financial reporting language. International Accounting Standards Board. London, 2016.

Royal Government of Cambodia. (2014). National Strategic Development Plan 2014 - 2018. Retrieved from: http://cdc-crdb.gov.kh/cdc/documents/NSDP_2014-2018.pdf

Royal Government of Cambodia. (2015). Cambodia Industrial Development Policy 2015 - 2025. Retrieved from: http://www.cambodiainvestment.gov.kh/content/uploads/2015/09/IDP-English-Version-FINAL1.pdf

Singapore Commodity Exchange. (2017). Rubber Number Three Smoked Sheet RSS3. Retrieved from: http://www.indexmundi.com/commodities/?commodity=rubber&months=60

Sothear, K. (2016). Rubber Export Volumes Rise, Value Falls. *Cambodia Daily*, Phnom Penh, January 28, 2016.

Trabelsi, R. (2016). Are IFRS Harder to Implement for Emerging Economies Compared to Developed Countries? A Literature Review. *Journal of Modern Accounting and Auditing*, January 2016, Vol 12, No. 1, 1-16. Retrieved from: http://www.davidpublisher.com/Public/uploads/Contribute/56946b13dbb98.pdf

Uyar, A.; Kilic, M; Gokcen, B. (2016). Compliance with IAS/IFRS and firm characteristics: evidence from the emerging capital market of Turkey. *Economic Research-Ekonomska Istrazivanja*, Routledge, Taylor and Francis, Vol. 29, No. 1, 148-161. Retrieved from: http://www.tandfonline.com/doi/full/10.1080/1331677X.2016.1163949